ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

២៥

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៧៧៩

ចុះថ្ងៃទី០៩-១០-២០០៦

សាលដីកា

លេខ : ៧៣ "ស"

ចុះថ្ងៃទី ២៤-១១-២០០៨

## នាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក[redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៧៧៩ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៦ ដែលមាន:**

- ជនជាប់ចោទឈ្មោះ [redacted]ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម មុខរបរមេផ្ទះ ប្តីឈ្មោ[redacted]នកូន ឪពុកឈ្មោះ[redacted] ម្តាយឈ្មោ[redacted] ទោសពីមុនគ្មាន ។

មានលោក[redacted]ាមេធាវីការពារ ។

ត្រូវជាប់ចោទពីបទ: បង្ករបួសស្នាមដោយចេតនា និងបរិហាកេរ្តិ៍ ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី ២៥-៤-២០០៥ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា ៤១ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

Scanned by CamScanner

- ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣៤ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម មុខរបរលក់ដូរ ប្តីឈ្មោះ [redacted]) មានកូន ០១នាក់ ឪពុក [redacted] ស) ម្តាយឈ្មោះ [redacted] ស) ទោសពីមុនគ្មាន។

<u>ត្រូវជាប់ចោទពីបទ</u>: បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី ២៥-៤-២០០៥ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា ៤១ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>**

កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ វេលាម៉ោង៦ល្ងាច ឈ្មោះ [redacted] បានចុះពីលើផ្ទះមកដល់ដី បានស្រែកហៅជីដូនឈ្មោះ [redacted] ឱ្យហុចក្រម៉ាយកទៅងូតទឹក ពេលឃើញឈ្មោះ [redacted] ពុងតែហាលខោអាវ ឈ្មោះ [redacted] ស្រែកឱ្យជីដូនរបៀបដៀមដាម ស្រាប់តែឈ្មោះ [redacted] ស្រែកឱ្យមកវិញថា មីតត្វនេះមើលមុខអញ ឈ្មោះ [redacted] បានស្រែកទៅវិញថា មីធិតប្តី រួចយកដុំថ្មគប់គ្នាទៅវិញទៅមក បណ្តាលឱ្យមានរបួសរៀង១ខ្លួន។

**បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៤៣ គ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសឈ្មោះ [redacted] ភេទស្រី អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់៦ខែ តែទោសនេះ ត្រូវព្យួររយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ពីបទ បង្ករបួសស្នាមដោយចេតនា និងបរិហាកេរ្តិ៍ ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី ២៥-៤-២០០៥ បទល្មើសដែលមានចែងឱ្យ ផ្តន្ទាទោសតាម មាត្រា ៤១ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ផ្តន្ទាទោសឈ្មោះ [redacted] ភេទស្រី អាយុ ៣៤ឆ្នាំ ដាក់ពន្ធនាគារកំណត់២ខែ តែទោសនេះ ត្រូវព្យួររយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ពីបទ បង្ករបួសស្នាមដោយចេតនា និងបរិហាកេរ្តិ៍ ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី ២៥-៤-២០០៥ បទល្មើសដែលមានចែងឱ្យ ផ្តន្ទាទោសតាម មាត្រា ៤១ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២- បង្គាប់ឱ្យឈ្មោះ [redacted] សងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តចំនួន៣.០០០.០០០រៀល ឱ្យទៅ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឱ្យឈ្មោះ [redacted] សងសំណង និងថ្នាំព្យាបាលចំនួន ១.០០០.០០០រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ការប្តឹងទាមទារលើសពីនេះលើកចោល។ ក្នុងករណីឈ្មោះទាំង២នេះ មិនព្រមសងប្រាក់ធនទណ្ឌទេ អនុញ្ញាតឱ្យចាប់ដាក់គុកបង្ខំលើរូបកាយ តាមមាត្រា ៧ នៃ ច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៣- សាលក្រមនេះជំនុំជម្រះជាសាធារណៈ ប្រកាសចំពោះមុខជនល្មើស និងត្រូវជាដើមបណ្តឹងរដ្ឋប្បវេណី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។



Scanned by CamScanner

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោ[redacted]សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៣ គ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ របស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោ[redacted] (វត្តមាន)
- ជនជាប់ចោទឈ្មោះ [redacted] (វត្តមាន)
- លោក [redacted]ជាមេធាវីការពារជនជាប់ចោទឈ្មោ[redacted] (វត្តមាន)

ជនជាប់ចោទឈ្មោះ [redacted]ឆ្លើយថាៈ នៅថ្ងៃកើតហេតុនោះ ខ្លួនមុជទឹក ខ្លួនស្រែកឱ្យយាយខ្លួនយកក្រមាស្រាប់តែឈ្មោ[redacted]កថា ម្តេចមើលមុខអញ ខ្លួនក៏តបវិញថា អញមើលផងមិនបាន ភ្លាមនោះឈ្មោះ[redacted] បានរើសដុំថ្មគប់មកចំក្បាលជង្គង់ខ្លួន ហើយឈ្មោះ [redacted] នេះ បានហែករបងចង់មកវ៉ៃខ្លួនទៀត តែត្រូវទាក់សារុងនឹងរបងធ្វើឱ្យដួលត្រូវរបួស ។ ខ្លួនពុំបានយកដុំថ្មគប់[redacted]។ សំណូមពរ សូមតុលាការសម្រេចឱ្យខ្លួនផុតពីបទចោទប្រកាន់ផង ។

ជនជាប់ចោទឈ្មោ[redacted]យថាៈ នៅថ្ងៃកើតហេតុនោះ ខ្លួនកំពុងតែហាលខោអាវ ស្រាប់តែ[redacted]កថា ឱ្យយាយរបស់គេមើលមីផិតឬ ដោយស្រែកដដែលៗច្រើនដង ខ្លួនទ្រាំពុំបានក៏តបវិញថា មីស្វេញអញធ្វើអ្វីហ្វងអែងបានជាជេរអញ ពេល[redacted]នរើសដុំថ្មគប់ខ្លួន ត្រូវចំភ្នែកឆ្វេងឡើងជាំ សព្វថ្ងៃនេះ ភ្នែកខ្លួនមើលពុំច្បាស់ទេ ចេះតែស្រវាំង ។ សំណូមពរ សូមតុលាការសម្រេចតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការ ។

តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើសេចក្តីសន្និដ្ឋានថាៈ មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted]ទ បរិហាកេរ្តិ៍ និង[redacted]បទ បង្ករបួសស្នាមដោយចេតនា តាមមាត្រា ៤១ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ហេតុដូច្នេះ តំណាងមហាអយ្យការសូមសន្និដ្ឋាន សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៣ គ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការទាំងមូល ។

លោក [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋានថាៈ នៅថ្ងៃកើតហេតុនោះ កូនក្តីខ្លួនពុំបានចោលដុំថ្មទៅលើឈ្មោះ[redacted] គឺ[redacted]ាក់ជើងដួលត្រូវមុខដោយខ្លួនឯងទេ ។ សូមក្រុមប្រឹក្សាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ



Scanned by CamScanner

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទឈ្មោះ [redacted]

ក្រោយពីបានពិនិត្យពិភាក្សានិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹង សាលក្រមព្រហ្មទណ្ឌលេខ ៤៣ ត ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ចាម គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន ។

២- កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ ឈ្មោះ [redacted] និងឈ្មោះ [redacted] មានទំនាស់ពាក្យសម្តីគ្នា ហើយក្នុងខណៈនោះ ឈ្មោះ [redacted] ជេរឈ្មោះ [redacted] ថា មីសត្វ ឯឈ្មោះ [redacted] តបវិញថា មីជិតប្តី ។ បន្ទាប់មកក៏រើសដុំថ្មគប់គ្នាទៅវិញទៅមក បណ្តាលឱ្យមានរបួសរៀង១ខ្លួន ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទទាំង២នាក់ ពីបទ បង្ករបួសដោយចេតនា និងបទ បរិហាកេរ្តិ៍ តាមមាត្រា ៦៣ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៤១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលគប្បីជនទាំង២នាក់នេះមានការទទួលខុសត្រូវតាមបញ្ញត្តិច្បាប់ ។

៣- សាលក្រមព្រហ្មទណ្ឌដែលសាលាដំបូងខេត្តកំពង់ចាម បានសម្រេចមកនេះ មានលើកសំអាងហេតុសព្វគ្រប់ហើយ សភាព្រហ្មទណ្ឌឯកភាពលើសំអាងហេតុទាំងនេះ ហេតុដូច្នេះ សភាព្រហ្មទណ្ឌមិនចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៤៣ ត ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដែលគប្បីសភាព្រហ្មទណ្ឌសម្រេចតម្កល់ទុកជាបានការតទៅ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៨-៦-២០០៦ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានតតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៣ (ត) ចុះថ្ងៃទី ០៨-៦-២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ។



Scanned by CamScanner

៣- សាលដីកានេះជំនុំជម្រះនិងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤-១១-២០០៨ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១៤ ខែ ៧ ឆ្នាំ ២០០៩

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned by CamScanner